Nº 38
15.10.97

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣៨ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- **ច្បាប់**
- **ក្រម-ក្រឹត្យ**
- **អនុក្រឹត្យ**
- **ប្រកាស**
- **សេចក្ដីសម្រេច**
- **សារាចរ**

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I — ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១២-១០-១៩៩៧ –ព្រះរាជក្រឹត្យ នស / រកត / ១០៩៧ / ៦៦ តែងតាំងលោក សោម ឆេង ជាឧកញ៉ា ២១៦៨

II — រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៣-១០-១៩៩៧ –អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ សំរាប់ទិញដែកបេឡេត៍ប្រវែង ៤០០ ម៉ែត្រ កសាងផ្លូវលើកកូវិតក្នុងផែនការឆ្នាំ ១៩៩៧ ២១៦៩

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២១៧០

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពីការផ្ទេរឥណទាន ២១៨១

១៥-១០-១៩៩៧ –អនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពីកាតព្វកិច្ចធ្វើស្ថិតិ ២១៨៣

១០-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩២ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២១៩១

១០-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៣ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២១៩៣

១០-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៤ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២១៩៥

១០-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៥ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២១៩៦

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៦ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២១៩៧

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៧ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២១៩៨

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២២០០

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ២២០១

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០២

១៤-១០-១៩៩៧ –អនុក្រឹត្យលេខ ២០១ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០៣

III — ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាស

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤២ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០៤

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤២ ប្រក.(ស្ទួន) ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០៥

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤៣ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០៦

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤៣ ប្រក.(ស្ទួន) ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០៧

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤៤ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០៨

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤៤ ប្រក.(ស្ទួន) ស្តីពីការតែងតាំងមន្ត្រីរាជការ ២២១០

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤៥ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២២១១

១៤-១០-១៩៩៧ –ប្រកាសលេខ ១៤៥ ប្រក.(ស្ទួន) ស្តីពីការតែងតាំងមន្ត្រីរាជការ ២២១២

១៥-១០-១៩៩៧ –ប្រកាសលេខ ១៤៧ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២២១៣

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

១៤-១០-១៩៩៧ –ប្រកាសលេខ ២៨៩ ពណ. ពកប. ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ២២២០

១៥-១០-១៩៩៧ –ប្រកាសលេខ ២៩១ ពណ. ពកប. ប្រក ពុំអនុញ្ញាតអោយក្រុមហ៊ុនជិពាក់ឯកសារ ដែលពាក់ព័ន្ធដល់បែបបទផ្តល់វិញ្ញាបនប័ត្រដើមទំនិញពិសេស CP ២២២២

គី

៣– ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៥-១០-១៩៩៧	–ប្រកាសលេខ ៩៥៣ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ស៊ូជំរ ហ្វាយន៍ក្លស្សិន តំណាងដោយលោក FAN CHIANG CHENG សញ្ជាតិចិនតៃវ៉ាន់ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ	២២២៤
១៥-១០-១៩៩៧	–ប្រកាសលេខ ៩៥៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន គ្គែតភី ហ្គាមែនហ្វាក់ត្វរី (ខេមបូឌា) អិលធីឌី តំណាងដោយលោក LEE TUNG FUK សញ្ជាតិចិនហុងកុង បង្កើតរោងចក្រកាត់សំលៀកបំពាក់នាំចេញ	២២២៦
១៥-១០-១៩៩៧	–ប្រកាសលេខ ៩៥៥ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ្វ៊ររូម ហ្គាមែន ហ្វាក់ធរី តំណាងដោយលោក CHAN FRANKIE TAK HONG សញ្ជាតិអង់គ្លេស បង្កើតរោងចក្រកាត់សំលៀកបំពាក់នាំចេញ	២២២៨

៤– ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១៤-១០-៩៧	ប្រកាសលេខ ២៧៥/៩៧/ពមប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	២២៣០

៥–ទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ សាសនា

ប្រកាស

១៤-១០-១៩៩៧	–ប្រកាសលេខ ២០៩/៩៧ កធស. ស្តីពីការអនុញ្ញាតិអោយបញ្ចូលកម្មវិធីសិក្សាសិទ្ធិមនុស្សក្នុងប្រព័ន្ធពុទ្ធិកសិក្សា	២២៣១

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/១០៩៧/៦៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក សោម សេង

ជា

ឧកញ៉ា

ធ្វើនៅសៀមរាប ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៧

ព្រះហស្ថលេខា

នរោត្តម សីហនុ

II- រាជរដ្ឋាភិបាល

អនុក្រឹត្យ

អនុក្រឹត្យលេខ ៦១ អនក្រ.បក

ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីកម្មសហគ្រាស សាធារណៈ សំរាប់និញដែកបេឡាត់ប្រវែង ៤០០ ម៉ែត្រ កសាងផ្លូវលើកកំរិតក្នុងផែនការឆ្នាំ ១៩៩៧

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១ សប្រក ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីកម្មសហគ្រាសសាធារណៈ

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រើប្រាស់គណនី ឯកជន ភារ្យបនីយកម្មសហគ្រាសសាធារណៈដែលត្រូវបានបង្កើតឡើងតាមមាត្រា៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដើម្បីទិញដែកបេឡេតប្រវែង ៤០០ ម៉ែត្រ យកទៅកសាងស្ពានលើផ្លូវលើកគិតក្នុងផែនការឆ្នាំ១៩៩៧ របស់ក្រសួងសាធារណៈការ និង ដឹកជញ្ជូន មានទឹកប្រាក់ ១៤.៩៥០.០០០ $ (មួយលានបួនរយកៅសិបប្រាំពាន់ ដុល្លារអាមេរិក) ។

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ មានអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ៦២ អនក្រ.បក
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារ បេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- តាមការអនុម័តគណៈរដ្ឋមន្ត្រីនាថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

ជំពូក ២

បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២ : ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យវប្បធម៌ និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមានមុខងារ និងភារកិច្ចដូចតទៅ :

- ប្រតិបត្តិនូវនយោបាយការពារ ថែរក្សា និងលើកតំលៃបេតិកភ័ណ្ឌ វប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅ នៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងបណ្ណារមន្ទីរ ដ្ឋានបុរាណវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា
- ថ្មីឡើងវិញ និងលើកតំកើងបណ្តាតំលៃវប្បធម៌ និងជំនឿទំនៀមទំលាប់ប្រពៃណីរបស់សង្គមជាតិ បំផុសការបង្កើតស្នាដៃ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ សកម្មភាពវប្បធម៌
- ជាអាណាព្យាបាលលើសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងការបណ្តុះបណ្តាលសិល្បករ តន្ត្រីករ ស្ថាបត្យករ បុរាណវិទូ និងអ្នកជំនាញផ្សេងៗទៀត ដែលពាក់ព័ន្ធនឹង វិស័យវប្បធម៌ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានរចនាសម្ព័ន្ធដូចតទៅ :

ក_នៅថ្នាក់កណ្តាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន
- នាយកដ្ឋានសិល្បៈ និង ទស្សនីយភាព
- នាយកដ្ឋានបេតិកភ័ណ្ឌ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានបច្ចេកទេសវប្បធម៌
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

ខ_អង្គភាពមូលដ្ឋាន

- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង

_ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ស្រុក ខ័ណ្ឌ ។

អង្គការលេខរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ជំពូក ៣

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥ : ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូក ៤

អធិការដ្ឋាន

មាត្រា ៦ : អធិការដ្ឋានរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈទទួលបន្ទុក :

_ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

_ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ

_ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ទុកចិត្ត

អធិការដ្ឋានដឹកនាំដោយអធិការមួយនាក់ អមដោយអធិការរងមួយ ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់

ជំពូក ៥

នាយកដ្ឋានសិល្បៈ _ ទស្សនីយភាព

មាត្រា ៧ : នាយកដ្ឋានសិល្បៈ ទស្សនីយភាព ទទួលបន្ទុក :

_លើកទឹកចិត្តការបង្កើតស្នាដៃធ្វើអោយសិប្បវបែប ព្រមទាំងផ្សព្វផ្សាយ យ៉ាងទូលំទូលាយនូវទស្សនីយភាពរស់ មានវិស័យល្ខោន តន្ត្រី របាំ សៀក និងទស្សនីយ

ភាពផ្សេកៗផងទៀត

-កំណត់នូវនយោបាយវិមជ្ឈការអំពីជំនាញសិល្បៈ ចំពោះបណ្តាក្រុមសិល្បៈតាមខេត្ត ក្រុងទូទាំងប្រទេស

-សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងការបណ្តុះបណ្តាលសិល្បៈករ នៃវិស័យសិល្បៈរស់

-លើកឡើងនូវនយោបាយអំពីការពិចារណា និង ការកែសម្រួលបណ្តាវិជ្ជាជីវៈ និងការ រៀបចំវិស័យសិល្បៈ

-សិក្សាអំពីសកម្មភាពទាំងឡាយសំដៅ ពង្រីកទស្សនិកជន ។ នាយកដ្ឋានសិល្បៈ ទស្សនីយភាព ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាន នាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ជំពូក ៦

នាយកដ្ឋានបេតិកភណ្ឌ

មាត្រា ៨ : នាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុក ៖

-សិក្សាការពារអភិរក្ស និង ធ្វើអោយមានតំលៃចំពោះរាល់ផ្នែកនៃបេតិកភណ្ឌ វប្បធម៌ជាតិ ពិសេសចំពោះបេតិកភណ្ឌនៃវិមាននិងបុរាណវិទ្យា វត្ថុជាប្រវត្តិសាស្ត្រ សមុច្ច័យរូបថត បេតិកភ័ណ្ឌនៃជាតិពិន្ទុវិទ្យា និងបណ្តារមណីយដ្ឋាន ដែលត្រូវ ការពារ ក្រៅពីរមណីយដ្ឋានធម្មជាតិ និង កែច្នៃ ។

-រៀបចំផែនដី ផ្នែកវប្បធម៌សំដៅអនុវត្តកម្មវិធីនៃការធ្វើនីតិសម្បទាវប្បធម៌នៅទូ ទាំងប្រទេស ។

នាយកដ្ឋានបេតិកភ័ណ្ឌដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ជំពូក ៧

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៩ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានមុខងារដូចតទៅ :

-គ្រប់គ្រងការងាររួមមាន : រដ្ឋបាល-បូកសរុប របាយការណ៍-ឯកសារ-បុគ្គលិក ផែន-ការហិរញ្ញវត្ថុ-សម្ភារៈបរិក្ខារ-ការងារបណ្តុះបណ្តាលក្របខ័ណ្ឌក្រសួង ការងារសិក្សាស្រាវជ្រាវ និងធ្វើតុល្យភាពការងារ ។

-សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួងជាមួយបណ្តាអង្គភាពមូលដ្ឋាន ខេត្ត ក្រុង និងជាមួយបណ្តាក្រសួងនានា ។

មាត្រា ១០ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុត្រូវដឹកនាំដោយ អគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជួយធ្វើការទៅតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមាននាយកដ្ឋានចំណុះចំនួន ៥ និងសាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ថ្នាក់ស្មើនាយកដ្ឋាន :

១_នាយកដ្ឋានរដ្ឋបាលទូទៅ

២_នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

៣_នាយកដ្ឋានសម្ភារៈ និងបរិក្ខារ

៤_នាយកដ្ឋានសិក្សាស្រាវជ្រាវ និងតុល្យភាពការងារ

៥_នាយកដ្ឋានបុគ្គលិក

៦_សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ។

មាត្រា ១១ : នាយកដ្ឋានរដ្ឋបាលទូទៅ ទទួលបន្ទុក :

_សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ

_គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង

_ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល

_សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

មាត្រា ១២ : នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុទទួលបន្ទុក :

- ប្រមូលចំណូល អោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់
- លើកគំរោងថវិកាក្រសួង និងតាមដានវិលើកពីការប្រតិបត្តិ
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា
- តាមដានវិលើកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

មាត្រា ១៣ : នាយកដ្ឋានសម្ភារៈ និងបរិក្ខារទទួលបន្ទុក :

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គូសផុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត-ក្រុងនានា
- កាន់បញ្ជីជាប្រចាំនូវសលាកបត្រ និងគណនេយ្យបជាតុ
- ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

មាត្រា ១៤ : នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគុណភាពការងារទទួលបន្ទុក :

- ធ្វើអោយសំរេច និងផ្សព្វផ្សាយនូវការងារសិក្សា ស្រាវជ្រាវ និងបូកសរុបដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ចនៃវិស័យវប្បធម៌ ព្រមទាំងផ្ទៀងផ្ទាត់ការប្រើប្រាស់ បានល្អនូវបណ្តាលទ្ធផលទាំងនោះ
- សិក្សាពិចារណាលើវិធីសាស្ត្រធ្វើការងារក្នុងក្រសួង ព្រមទាំងលើកសំណើផ្សេងៗ ដើម្បីកែសម្រួល

-រៀបចំគំរោងផែនការអំពីតម្រូវការចាំបាច់នានារបស់ក្រសួង ដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ និងសុំជំនួយឧបត្ថម្ភផ្សេងៗ។

-សហការជាមួយក្រសួងផែនការ ដើម្បីរៀបចំប្រព័ន្ធស្ថិតិមួយ អំពីជីវភាពវប្បធម៌ទូទាំងប្រទេស

- រៀបចំចងក្រងកម្មវិធីវប្បធម៌ សំរាប់ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍

មាត្រា ១៥ : នាយកដ្ឋានបុគ្គលិក ទទួលបន្ទុក :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនិងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព

-ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតម្រែតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក

-រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

-គ្រប់គ្រងការងារសង្គមរបស់ក្រសួង

មាត្រា ១៦ : សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ (ដោយធ្វើទំនាក់ទំនងជាមួយសាលាភូមិន្ទរដ្ឋបាល) ទទួលបន្ទុក :

-រៀបចំប្រឡងជ្រើសរើសបញ្ចូលក្របខ័ណ្ឌក្រសួង អោយសមស្របតាមនយោបាយបុគ្គលិករួមរបស់ក្រសួង

-ធ្វើការបណ្តុះបណ្តាលនូវមុខជំនាញចាំបាច់ មុនបញ្ចូលជាក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង

-រៀបចំធ្វើក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង

_រៀបរៀងកម្មវិធីសិក្សាសមស្រប តាមការរៀបចំក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង។

ជំពូក ៨

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

មាត្រា ១៧ : អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មានមុខងារអនុវត្តនូវរាល់បេសកកម្ម របស់ក្រសួង ក្នុងការប្រតិបត្តិនយោបាយលើវិស័យ :

បេតិកភណ្ឌ សារៈមន្ទីរ សិល្បៈសូនរូប សៀវភៅ និងការអានសាធារណៈ ភាពយន្ត វីដេអូ និង ពហុមេឌីយ៉ា អភិវឌ្ឍន៍វប្បធម៌ និង អប់រំសិល្បៈ ។

មាត្រា ១៨ : អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួន ជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានបច្ចេកទេស មាននាយកដ្ឋានចំរុះចំនួន ៥ :

១_នាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌

២_នាយកដ្ឋាន សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌

៣_នាយកដ្ឋាន សារៈមន្ទីរ

៤_នាយកដ្ឋាន សិល្បៈសូនរូប និង សិប្បកម្ម

៥_នាយកដ្ឋាន សៀវភៅ និងការអាន

មាត្រា ១៩ : នាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌ទទួលបន្ទុក :

_លើកទឹកចិត្តរាល់សកម្មភាពវប្បធម៌ ព្រមទាំងរៀបចំចាត់តាំងបណ្តាការសំដែងសិល្បៈវប្បធម៌ ពិពិរណ៍សំដៅធ្វើអោយមហាជន ចាប់អារម្មណ៍នឹងវប្បធម៌របស់ខ្លួន

_បំផុសនិងសម្រួលសមាគមវិជ្ជាជីវៈផ្សេងៗ ក្នុងវិស័យវប្បធម៌សំដៅលើកំពស់មនសិការវិជ្ជាជីវៈ ព្រមទាំងការពារផលប្រយោជន៍ ស្របច្បាប់របស់គេ

_លើកទឹកចិត្តនិងត្រួតពិនិត្យចំពោះការថែរក្សា រាល់សកម្មភាពវប្បធម៌ល្អៗ របស់ប្រជាពលរដ្ឋតាមតំបន់ទូទាំងប្រទេស

មាត្រា ២០ : នាយកដ្ឋាន សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ទទួលបន្ទុក :

- តំរង់ទិស និង លើកទឹកចិត្តក្នុងការផ្សព្វផ្សាយវប្បធម៌ និងសិល្បៈ តាមភាពយន្ត វីដេអូ និងពហុមេឌីយ៉ា
- សិក្សា និងអនុញ្ញាតការធ្វើអាជីវកម្មសិល្បៈទី៧ ជាភាពយន្តនិងវីដេអូ
- រក្សាឯកសារភាពយន្ត និងវីដេអូជាតិ
- អនុញ្ញាត និងលើកទឹកចិត្ត ធ្វើអោយអភិវឌ្ឍន៍សិល្បៈទី៧ ក្នុងរូបភាពជាភាពយន្ត និងវីដេអូ
- ផលិតផ្សព្វផ្សាយគ្រប់គ្រង និងត្រួតពិនិត្យវិស័យវប្បធម៌តាមរូបភាព ភាពយន្ត វីដេអូ និងពហុមេឌីយ៉ា ដោយសហការមួយក្រសួងពាក់ព័ន្ធ
- បណ្តុះបណ្តាល បំពាក់បំប៉នមុខជំនាញភាពយន្ត និង វីដេអូ ។

មាត្រា ២១ : នាយកដ្ឋាន សារៈមន្ទីរ ទទួលបន្ទុក :

- គ្រប់គ្រងការភិរក្ស ការថែរក្សា ការជួសជុល ការសិក្សា និងការធ្វើអោយសំបូរបែបនៃសមុច្ច័យសាធារណៈ ។
- ធានាការផ្សព្វផ្សាយ និងការតាំងបង្ហាញសមុច្ច័យទាំងឡាយ ចំពោះសាធារណៈជន ព្រមទាំងត្រួតពិនិត្យ តាមលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បណ្តាសមុច្ច័យទាំងនោះ ។
- ជាអាណាព្យាបាលលើសារមន្ទីររដ្ឋ និងសារមន្ទីរគ្រប់ប្រភេទនៅទូទាំងប្រទេស

មាត្រា ២២ : នាយកដ្ឋានសិល្បៈសូន្យរូប និង សិប្បកម្មទទួលបន្ទុកតំរង់ទិសបំផុសការបង្កើតស្នាដៃ និងលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃ ព្រមទាំងផ្សព្វផ្សាយក្នុងចំណោមមហាជននូវរាល់រូបភាពសិល្បៈសូន្យរូប និងសិប្បកម្មសិល្បៈ ។

មាត្រា ២៣ : នាយកដ្ឋានសៀវភៅ និងការអាន ទទួលបន្ទុក :

- ថែរក្សាការពារ និងលើកតំកើងរាល់ស្នាដៃសរសេរ ដែលបានរក្សាទុក និង

តំកល់ទុកតាមច្បាប់

- ទ្រទ្រង់ចំពោះសៀវភៅគ្រប់ប្រភេទ បង្កលក្ខណៈងាយស្រួលក្នុងការបង្កើតចេញជាសៀវភៅ និងជួយគាំពារចំពោះការផ្សព្វផ្សាយ
- ធ្វើអោយសៀវភៅទៅដល់មនុស្សគ្រប់រូប តាមរយៈការអានជាសាធារណៈ
- គ្រប់គ្រងបណ្ណាល័យជាតិ និងបណ្ណាល័យតាមខេត្ត
- អនុញ្ញាតអោយបើក និងត្រួតពិនិត្យបណ្ណាល័យគ្រប់ប្រភេទ ។

ជំពូក ៩

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

មាត្រា ២៤ : សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានមុខងាររៀបចំការបណ្តុះបណ្តាលសិល្បៈករ តន្ត្រីករ ស្ថាបត្យករ បុរាណវិទូ និងជំនាញផ្សេងទៀត ដែលពាក់ព័ន្ធ នឹងវិស័យវប្បធម៌ ។ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានឋានៈសមមូលអគ្គ នាយកដ្ឋាន ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃសាកវិទ្យាភូមិន្ទវិចិត្រសិល្បៈ និងត្រូវរៀបចំដោយអនុក្រឹត្យមួយដោយឡែក ។

ជំពូក ១០

អង្គភាពមូលដ្ឋាន

មាត្រា ២៥ : នៅតាមខេត្ត ក្រុងនីមួយៗមានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុងមួយដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង ។

ជំពូក ១១

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២៦ : អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការ

ចំណាយថវិកាក្នុងបណ្តាក្រសួង ។

ជំពូក ១២

អវសានបញ្ញត្តិ

មាត្រា ២៧ : ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោម នាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ

មាត្រា ២៨ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុករៀង ៗខ្លួនអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ៦៣ អនក្រ.បក

ស្តីពីការផ្ទេរតំណែងនាយ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣

ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម០១៩៦/១៨ ៩៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៧
- បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៤ និង ប្រកាសស្តីពីការកែប្រែ និង បំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៤, លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ១៩៩៥, លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥, លេខ ៣៣៖ ប្រក.សហវ.ថ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ១៩៩៥, លេខ ០៧៖ ប្រក.សហវ.ថ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩៩៦

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយឥណទាន ពីជំពូក៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌) ចំនួន ៦៧៤.៩០០.០០០ រៀល (ប្រាំមួយរយចិតសិបបួនលាន ប្រាំបួនរយពាន់រៀលគត់) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មក ជំពូក៣១ របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២ : ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បើកផ្តល់អាហារូបករណ៍ និង របបឧបត្ថម្ភជីវភាព អន្តេវាសិក នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង ខេត្តក្រុង ។

មាត្រា ៣ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យលេខ ៦៤ អនក្រ.បក

ស្តីពីភាគពុកិច្ចធ្វើស្ថិតិ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួង ផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងផែនការ
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ១០ ខែកក្កដា ឆ្នាំ១៩៩៧

សម្រេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះគ្រប់គ្រងបណ្តាការងារដែលទាក់ទងនឹង ការប្រមូល ការចងក្រង ការកែច្នៃ ការបោះពុម្ព និង ផ្សព្វផ្សាយទិន្នន័យស្ថិតិ និងពត៌មាន ពីលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ច របស់ប្រជារាស្ត្រ គ្រឹះស្ថាន សហគ្រាសឯកជន និងរដ្ឋ រួមមានស្ថិតិប្រជារាស្ត្រ ទិន្នន័យគណនេយ្យជាតិ ថ្លៃទំនិញប្រើប្រាស់ និងថ្លៃសេវាកម្មទូទាំងព្រះរាជាណាចក្រកម្ពុជា និងការដែលទាក់ទង និងទិន្នន័យ ស្ថិតិពត៌មានខាងលើ ។

មាត្រា ២ : វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការមានភារកិច្ចអនុវត្តមាត្រា១ ខាងលើ ។

ជំពូកទី ២

សមត្ថកិច្ចក្នុងការធ្វើជំរឿន ឬអង្កេត

មាត្រា ៣ : រដ្ឋមន្ត្រីក្រសួងផែនការ ធ្វើសំណើជាលាយលក្ខអក្សរ អំពីគំរោងស្ថិតិ ស្តីពីការធ្វើជំរឿន ឬអង្កេតជាតិ ដាក់សុំសេចក្តីអនុញ្ញាតពីគណៈរដ្ឋមន្ត្រី ដោយត្រូវរាយលំអិតអំពី :

ក_គោលដៅនៃការធ្វើជំរឿន ឬអង្កេត

ខ_វិស័យដែលបានកំណត់សំរាប់ ការធ្វើជំរឿន ឬអង្កេត

គ_រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាមុខសញ្ញាត្រូវឆ្លើយបំពេញតារាងសំណួរ ឬកំរងសំណួរ

ឃ_អង្គភាពស្ថិតិតាមបណ្តាក្រសួង និងអាជ្ញាធរខេត្ត ក្រុង និងអង្គភាពនានាដែលត្រូវទទួលអនុវត្តការធ្វើជំរឿន ឬអង្កេត

ង_បញ្ហាទាំងឡាយដែលមានសារសំខាន់ ទាក់ទងនិងការធ្វើជំរឿន ឬអង្កេត ។

មាត្រា ៤ : វិទ្យាស្ថានជាតិស្ថិតិ ត្រូវដឹកនាំធ្វើការជំរឿន ឬអង្កេត ក្រោយពីមានការអនុញ្ញាតពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

មាត្រា ៥ : រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវធ្វើប្រកាស ឬសេចក្តីណែនាំដល់បណ្តាក្រសួង ស្ថាប័ន ឬអាជ្ញាធរខេត្ត-ក្រុងពីការធ្វើជំរឿន ឬអង្កេត ក្រោយពីបានការទទួលការអនុញ្ញាតពីគណៈរដ្ឋមន្ត្រី ។

ជំពូកទី ៣

ការប្រមូលពត៌មាន

មាត្រា ៦ : នាយកវិទ្យាស្ថានជាតិស្ថិតិ មានសិទ្ធិចាត់តាំងមន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ ធ្វើការប្រមូលយកពត៌មានស្ថិតិផ្ទាល់ពី រូបវន្តបុគ្គល ឬនីតិបុគ្គល តាមការកំណត់របស់វិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា ៧ : នាយកវិទ្យាស្ថានជាតិស្ថិតិ ត្រូវរៀបចំ និងធ្វើការណែនាំពីការប្រើប្រាស់ កំរងសំណួរ តារាងសំណួរ ចំណាត់ថ្នាក់ពតិមានស្ថិតិ បែបបទចាំបាច់ផ្សេងៗ និងកំណត់កាលបរិច្ឆេទ សំរាប់ការប្រមូលពតិមានស្ថិតិ ។

មាត្រា ៨ : នាយកវិទ្យាស្ថានជាតិស្ថិតិ មានសិទ្ធិផ្តល់កំរងសំណួរ ឬតារាងសំណួរសុំអោយ រូបវន្តបុគ្គល ឬនីតិបុគ្គល ផ្តល់ពតិមានតាម កាលវេលាជាក់លាក់ ឬ ចន្លោះកាលវេលាទៀងទាត់មកវិទ្យាស្ថានជាតិស្ថិតិ ។ ការផ្តល់កំរងសំណួរ ឬតារាងសំណួរអោយបំពេញអាច :-

- ប្រគល់ផ្ទាល់ដៃដល់សាមីខ្លួន
- ផ្ញើតាមប្រៃសណីយ៍ដោយមានសរសេរអាស័យដ្ឋានច្បាស់លាស់
- ផ្ញើតាមអ្នកដែលស្គាល់សាមីជន ឬ
- ប្រគល់ផ្ទាល់ដៃដល់អ្នកដែលបានទទួលសិទ្ធិធ្វើជំនួសបុគ្គលនោះ ។

ជំពូកទី ៤

ភារកិច្ច និងសិទ្ធិរបស់អ្នកផ្តល់ពតិមាន

មាត្រា ៩ : អ្នកផ្តល់ពតិមាន ដែលមានភារកិច្ចផ្តល់ពតិមាន ត្រូវផ្តល់ពតិមានអោយបានត្រឹមត្រូវ និងស្មោះត្រង់ តាមគ្រប់សំណួរដែលកំណត់ឡើង ដោយវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា ១០ : ករណីដែលមិនទាន់មានពតិមានត្រឹមត្រូវ និង គ្រប់គ្រាន់ អ្នកផ្តល់ពតិមាន ប៉ាន់ស្មានដែលសមស្របមកវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា ១១ : អ្នកផ្តល់ពតិមាន ត្រូវផ្តល់ភាពងាយស្រួល សមរម្យ ដូចជា ការបង្ហាញឯកសារ និងសំណៅកត់ត្រានានា ដើម្បីអោយមន្ត្រីស្ថិតិដែលបានចាត់តាំងបំពេញការងារល្អ ។

មាត្រា ១២ : ករណីដែលមានសំណួរស្រង់យកពតិមានស្ថិតិក្នុងការធ្វើជំរឿន ឬអង្កេត រូបវន្

បុគ្គល ឬនីតិបុគ្គលសាមីអ្នកផ្តល់ពត៌មាន មានសិទ្ធិសុំ រដ្ឋមន្ត្រីក្រសួងផែនការ ធ្វើការដកសំណួរនោះ ពីកំរងសំណួរ ឬតារាងសំណួរ សុំមិនអោយធ្វើការកែច្នៃ ការបោះពុម្ព ឬការផ្សព្វផ្សាយពត៌មានទាំងឡាយចេញពីសំណួរនោះ ។ រដ្ឋមន្ត្រីក្រសួងផែនការ ជាអ្នកសំរេចចុងក្រោយលើសំនួរនោះ ។

មាត្រា ១៣ : គ្មានបុគ្គលណាម្នាក់ ត្រូវបានបង្ខំអោយផ្តល់ពត៌មានអ្វី ដែលខ្លួនមិនបានដឹងនោះឡើយ ។

មាត្រា ១៤ : ពត៌មានក្នុងកំរងសំណួរ និងតារាងសំណួរ ត្រូវប្រើប្រាស់ឯកសារង្វាស់រង្វាល់ ជាផ្លូវការនៅកម្ពុជា ។

ជំពូកទី ៥
សិទ្ធិរបស់មន្ត្រីស្ថិតិ

មាត្រា ១៥ : មន្ត្រីស្ថិតិដែលបានចាត់តាំងអោយ ធ្វើការប្រមូលយកពត៌មានស្ថិតិ មានសិទ្ធិអនុវត្តកិច្ចការនៅតាមលំនៅឋាន ហាងលក់ទំនិញ ការិយាល័យ ឬទីកន្លែងប្រកបអាជីវកម្មរបស់បុគ្គលដែលត្រូវបំពេញ កំរងសំនួរ ឬតារាងកំរងសំណួរ ក្នុងចន្លោះពេលពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច ដើម្បីពិនិត្យភាពជាក់ស្តែង ឬឯកសារដែលទាក់ទងដល់ការបំពេញកំរងសំណួរ ឬតារាងសំណួរ ។

មាត្រា ១៦ : មន្ត្រីដែលបានចាត់តាំងអោយ ធ្វើការប្រមូលយកពត៌មានស្ថិតិ ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មផ្ទាល់ខ្លួន ដល់អ្នកផ្តល់ពត៌មានក្នុងការបំពេញ ភារកិច្ច ។

ជំពូកទី ៦
ការរក្សាការសម្ងាត់នៃពត៌មាន

មាត្រា ១៧ : ពត៌មានដែលផ្តល់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល មកវិទ្យាស្ថានជាតិស្ថិតិ ត្រូវ

ប្រើតែក្នុងគោលដៅស្ថិតិតែប៉ុណ្ណោះ ។

មាត្រា ១៨ : វិទ្យាស្ថានជាតិស្ថិតិ ត្រូវធានារក្សាការសម្ងាត់នៃពត៌មានទាំងឡាយ ដែលរូបវ័ន្ត
បុគ្គល ឬនីតិ បុគ្គលបានផ្តល់មកអោយវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា ១៩ : ជនគ្រប់រូបដែលមានភារកិច្ច ប្រមូល ចងក្រង កែច្នៃ បោះពុម្ព ឬផ្សព្វផ្សាយ
ទិន្នន័យស្ថិតិ ត្រូវធ្វើកិច្ចសន្យាជាលាយលក្ខអក្សរ ជាមួយវិទ្យាស្ថានជាតិស្ថិតិ
ដោយធានាមិនធ្វើអោយបែកការសម្ងាត់ ឬយកពត៌មានទៅប្រើប្រាស់ផ្ទុយ
គោលបំណងនៃអនុក្រឹត្យនេះ ។

មាត្រា ២០ : ក្រៅពីមន្ត្រីស្ថិតិដែលបានចាត់តាំង គ្មានបុគ្គលណាម្នាក់ មានសិទ្ធិមើលពត៌មាន
ឬ តារាងពត៌មាន របស់រូបវ័ន្តបុគ្គល ឬនីតិបុគ្គលឡើយ ។

មាត្រា ២១ : គ្មានមន្ត្រីស្ថិតិណាម្នាក់ ដែលបំពេញភារកិច្ចធ្វើ ការប្រមូល ការកែច្នៃ ការប
ស្រាយ ការបោះពុម្ព ឬការផ្សព្វផ្សាយពត៌មានស្ថិតិ មានសិទ្ធិផ្សាយ ឬផ្តល់ទៅ
ក្រៅនូវពត៌មាន ដែលខ្លួនទទួលបានក្នុងកិច្ចប្រតិបត្តិការស្ថិតិ លើកលែងតែក
ចាំបាច់ក្នុងភារកិច្ចរបស់ខ្លួន ។

មាត្រា ២២ : នាយកវិទ្យាស្ថានជាតិស្ថិតិ ត្រូវធានាខ្លឹមសារនៃតារាងស្ថិតិទាំងអស់ថា សុទ្ធតែ
បានរៀបចំតាមបែបបទដែលមានការការពារ ដោយមិនបង្ហាញពីពត៌មានដោយ
ឡែករបស់ រូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាមួយឡើយ ។

មាត្រា ២៣ : កំរងសំណួរ ឬតារាងសំណួរដែលបានបំពេញ ទោះជាផ្នែកណាមួយក៏ដោយមិន
ត្រូវយកទៅផ្សព្វផ្សាយដោយឡែកបានឡើយ ។

មាត្រា ២៤ : ហាមយកបណ្ណកំណត់ចំណាំក្នុងសៀវភៅ បញ្ជី ឯកសារ ឬការកត់ត្រាទាំងឡាយ
ដោយម៉ាស៊ីន ដែលបានរៀបចំដោយមន្ត្រីស្ថិតិ ឬដោយបុគ្គលណាម្នាក់ដែលបា
បេញផុត ពីភារកិច្ចរបស់ខ្លួនមកធ្វើជាភស្តុតាង នៅមុខតុលាការបានឡើយ ។

ជំពូកទី ៧

ការបោះពុម្ព និងការផ្សព្វផ្សាយ

មាត្រា ២៥ : នាយកវិទ្យាស្ថានជាតិស្ថិតិ ត្រូវទទួលខុសត្រូវក្នុងការសំរេច លើបែបបទ ទម្រង់ វិធីសាស្ត្រប្រើប្រាស់ និងពេលវេលាផ្សព្វផ្សាយពត៌មានស្ថិតិ ដែលរៀបចំឡើង ដោយវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា ២៦ : ដើម្បីធានាផលប្រយោជន៍សាធារណៈ រដ្ឋមន្ត្រីក្រសួងផែនការ អាចបញ្ជាអោយ នាយកវិទ្យាស្ថានជាតិស្ថិតិ បញ្ឈប់ការកែច្នៃទិន្នន័យ ការបោះពុម្ព ឬការផ្សព្វផ្សាយពត៌មានដែលទាក់ទងនឹងសំណួរណាមួយក្នុងការធ្វើជំរឿន ឬអង្កេត ។

មាត្រា ២៧ : នាយកវិទ្យាស្ថានជាតិស្ថិតិ ត្រូវសម្រួលពត៌មាន ដែលបានទទួលពីការធ្វើជំរឿន ឬ អង្កេតសំរាប់ចងក្រងជារបាយការណ៍ ដើម្បីបោះពុម្ព និង ផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ១៧ : នាយកវិទ្យាស្ថានជាតិស្ថិតិ ត្រូវរាយការណ៍ជាលាយលក្ខអក្សរពីលទ្ធផល សង្ខេបនៃការធ្វើជំរឿន និងអង្កេតកំរិតជាតិ ជូនរដ្ឋមន្ត្រីក្រសួងផែនការអោយបានក្នុងរយៈពេលមួយឆ្នាំយ៉ាងយូរ គិតពីថ្ងៃដែលបានបញ្ចប់ការប្រមូលពត៌មានក្នុងការធ្វើជំរឿន ឬអង្កេត ។

ជំពូកទី ៨

ទោសបញ្ញត្តិ

មាត្រា ២៩ : មន្ត្រីស្ថិតិដែលបានចាត់តាំងអោយធ្វើជំរឿន ឬអង្កេតដែល :

ក_ធ្វើអោយបែកការណ៍សម្ងាត់ ឬផ្តល់ពត៌ដែលបានមកពីការងារ ដល់បុគ្គលដែលមិនមែនជាមន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ

ខ_មិនយកចិត្តទុកដាក់ បដិសេធដោយមិនសមហេតុផល ក្នុងការគោរពបទបញ្ជា

ឬការដឹកនាំពីនាយកវិជ្ជាស្ថានជាតិស្ថិតិ ឬមន្ត្រីដែលបានទទួលការចាត់តាំង

គ_ប្រមាថមើលងាយ ឬសួរសំណួរខុសឆ្គងដោយចេតនា លើអ្នកផ្តល់ពត៌មាន

ឃ_កែក្រឡៃពត៌មានដោយចេតនា

ង_ជំរិតទារប្រាក់ ឬទទួលសំណូកពីអ្នកផ្តល់ពត៌មាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ រៀល (មួយរយពាន់រៀល) ដល់ ២៥០.០០០រៀល (ពីររយហាសិបពាន់រៀល) ។ ដោយឡែកមន្ត្រីស្ថិតិដែលជាមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មថ្នាក់ទី២ ដូចមានចែងក្នុងមាត្រា៤០ ជំពូកទី៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣០ : អ្នកផ្តល់ពត៌មានណាម្នាក់ ដែលមិនគោរពតាមសំណូមពរ របស់វិជ្ជាស្ថានជាតិស្ថិតិ ដូចបានចែងក្នុងមាត្រា ៦ និង ៨ ហើយ :

ក_បដិសេធមិនឆ្លើយតាមការដឹងឮរបស់ខ្លួន ឬផ្តល់ពត៌មានដោយបំភ្លៃខុសពីការពិតដោយចេតនាឬ

ខ_ក្លែងសញ្ញា ឬធ្វើអោយខូចសញ្ញា ឬកែពត៌មានខុសពីការពិត ឬផ្តល់តារាងខុសដោយចេតនាឬ

គ_មិនអនុញ្ញាតអោយមន្ត្រីស្ថិតិដែលបានចាត់តាំងចូលក្នុងទីធ្លាផ្ទះសំបែង ក្នុងរបងផ្ទះ ក្នុងទូក ក្នុងកប៉ាល់ ក្នុងសហគ្រាស ឬទីកន្លែងនានាតាមតម្រូវការងារនៃអនុក្រឹត្យនេះ ឬ

ឃ_ដកចេញ លុបចោល ដាក់ជំនួស ឬធ្វើអោយខូចខាតលិខិតនានា សញ្ញា ឬលេខ ដែលបានគូសចំណាំ ឬបិទផ្សព្វផ្សាយ សំរាប់គោលបំណងនៃការជំរឿន ឬការអង្កេត ឬមុនពេលបញ្ចប់ ការជំរឿ ឬ ការអង្កេត ឬ

ង_បដិសេធមិនគោរព ឬយកចិត្តទុកដាក់អនុវត្តមាត្រាណាមួយ នៃអនុក្រឹត្យនេះ

ឬបទបញ្ញត្តិ ដែលពាក់ព័ន្ធនឹងអនុក្រឹត្យនេះ
ត្រូវពិន័យជាប្រាក់ពី ២៥០.០០០ រៀល (ពីររយហាសិបពាន់រៀល) ដល់ ៥០០.០០០រៀល (ប្រាំរយពាន់រៀល) និងត្រូវអនុវត្តមាត្រា ៩ ឬ ១០ ឬ ១១ នៃអនុក្រឹត្យនេះ ។ ករណីអ្នកផ្តល់ពត៌មានបានបំពានលើរូបរាងកាយមន្ត្រីស្ថិតិដែលមានភារកិច្ចស្រង់យកពត៌មានស្ថិតិ ពីរូបវន្តបុគ្គលខ្លួន ឬ នីតិបុគ្គលខ្លួន នោះត្រូវផ្តន្ទាទោស តាមក្រមព្រហ្មទណ្ឌតាមពាក្យបណ្តឹងរបស់ក្រសួងផែនការ ។

ជំពូកទី ៩

អវសានបញ្ញត្តិ

មាត្រា ៣១ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣៣ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * *

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧

អនុក្រឹត្យលេខ ១៩២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន១១ រូប ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងព្រះវិហារ និងព្រះពុទ្ធរូបមួយព្រះអង្គ នៅក្នុងវត្តបាក់អំរែក ឃុំព្រែកល្ពង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ ÷

ក_មេដាយមាសស្ថាបនាជាតិ :

១_លោក **បាន ឡើន** ហៅ **គោគ** និង អ្នកស្រី **អ៊ុច ទីត** បច្ច័យចំនួន ៣០.៧៦២$US

២_លោកឧបាសក **ថោង ឡើម** និងឧបាសិកា **នួន សាទិន** បច្ច័យចំនួន ១១.៣៨៥$US

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១_ព្រះអង្គ **គីម ផន** បច្ច័យចំនួន ៨.៦៨៣$US

២_លោកឧបាសក **នួន សួម** និងឧបាសិកា **មាស យ៉ែម** បច្ច័យចំនួន ៦.៥១៨$US

៣_លោកឧបាសក **ករ៉ែន ហាក់** និងឧបាសិកា **គា ហ៊ន** បច្ច័យចំនួន ៥.១០០$US

គ_មេដាយសិរីវឌ្ឍស្ថាបនាជាតិ :

១_លោកឧបាសក ថេង ឌួន និងឧបាសិកា កែវ ហុង បច្ច័យចំនួន ៤.១០០$US

២_លោក តែត ឡើម និងអ្នកស្រី ហ៊ិន ថែន បច្ច័យចំនួន ៤.៦០០$US

៣_លោកឧបាសក ឈុំ ហ៊ិន និងឧបាសិកា ម៉ូ កែ បច្ច័យចំនួន ៤.២៧៦$US

៤_លោក ឡេ ពន្លក និងអ្នកស្រី ឡឿន បច្ច័យចំនួន ៤.០៦១$US

៥_លោកឧបាសក ម៉ិន ខឡន់ និងឧបាសិកា ស ស៊ុង បច្ច័យចំនួន ៣.៥៦៦$US

៦_លោកឧបាសក ដុះ ឡឿន និងឧបាសិកា អ៊ាន បច្ច័យចំនួន ៣.២០០$US

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៩៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង. ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនចំនួន ០២ រូបដែលបានចំណាយថវិកាផ្ទាល់ខ្លួនសាងសង់សមិទ្ធផលនានានៅក្នុងវត្ត សើរសង្គម ឃុំតានី និងវត្តប្រាប ឃុំដើមដូង ស្រុកអង្គជ័យ ខេត្តកំពត ដូចមានរាយ នាមខាងក្រោមនេះ ÷

១_លោក **ទឹម ម៉េងថៃ** និង លោកស្រី **ស៊ូ ស៊ីម** ទឹកប្រាក់ ៦៧.២៥០ $US

២_លោក **ឈិន មៀច** និងអ្នកស្រី **នាក់ ឃី** ទឹកប្រាក់ ៥៣.៨៣៦ $US

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៩៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនលោក DATOK TAM BICHEK ជាពាណិជ្ជករនៅប្រទេសម៉ាឡេស៊ី បានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីសាងសង់អាគារថ្មីចំនួន ០២ខ្នង នៅក្នុងភូមិ ប្រគរមៀត ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងនៅក្នុងឃុំអង្គបាន ស្រុកកងមាស ខេត្តកំពង់ចាម សរុបចំណាយទាំងអស់ ៤០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន
លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៩៥ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនអង្គការមូលនិធិកុមារ "DONBOSCO" ដែលបានជួយសាងសង់អាគារសិក្សា ០១ ខ្នង មាន ៥ បន្ទប់ នៅសាលាបឋម

សិក្សា បឹងតាព្រហ្ម សង្កាត់បឹងតាព្រហ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចំណាយអស់ទឹក ប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៩៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាជួយកសាងអាគារសិក្សានៅក្នុងសាលាបឋមសិក្សាបឹងកក់ ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ ÷

ក_មេដាយមាសស្ថាបនាជាតិ :

–លោក **GOTO FUMIO** ជនជាតិជប៉ុនបរិច្ចាគថវិកាចំនួន ១០.៣៩៥ ដុល្លារអាមេរិក

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

–អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ជុំម៉ាអ៊ុំ** បរិច្ចាគថវិកាចំនួន ៥.៨០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១៩៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤

_ បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

_ តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសបនាជាតិ ជូនសប្បុរសជនដែលបានបរិច្ចាគទ្រព្យសម្បត្តិជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ នៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ÷

១_លោក **អ៊ុង អ៊ា** ជួយកសាងផ្លូវថ្នល់ អាគារសិក្សា និងវត្តអារាម នៅក្នុងខេត្តកងមាស សំទឹកប្រាក់សរុប ៣៣៩.១២០$US

២_លោក **អ៊ុត ថ្លាង** ជួយកសាងផ្លូវថ្នល់ និងស្ពាន នៅក្នុងស្រុក កងមាស ខេត្តកំពង់ចាម អស់ទឹកប្រាក់សរុបចំនួន ១៧៧.៥០០$US

៣_លោក **ម៉ៅ តំរុណ** ជួយកសាងផ្លូវថ្នល់ និងសមិទ្ធផលមួយចំនួនទៀត នៅក្នុងស្រុកកងមាស អស់ទឹកប្រាក់សរុប ២៦៨.៣៧០$US

៤_អង្គការ វើដបាណា កសាងអាគារសិក្សានៅក្នុងស្រុកជើងព្រៃអស់ទឹកប្រាក់ ៥២.២៧០$US

